# I- ខុទ្ទកាល័យព្រះមហាក្សត្រ

## ព្រះរាជក្រម

### ព្រះរាជក្រម នស/រកម/១១០០/១០

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

****

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី០៨ ខែ មីនា ឆ្នាំ ១៩៩៩ ដែល ប្រកាសឲ្យប្រើជាផ្លូវការនូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១-១២-១៣-១៨-២២-២៤-២៦-២៨-៣០-៣៤-៥១-៩០-៩១-៩៣ និងមាត្រាទាំងឡាយនៃជំពូកទី៨ដល់ជំពូកទី១៤ នៃ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែល ប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសុខាភិបាល
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រី និងអំពីរដ្ឋមន្ត្រីក្រសួងសុខាភិបាល

## ប្រកាសអោយប្រើ

ច្បាប់ស្តីពីការគ្រប់គ្រងលើការប្រកបវិជ្ជាជីវៈឯកជនក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី០២ ខែសីហា ឆ្នាំ២០០០ នាសម័យប្រជុំពេញអង្គលើកទី៤ នីតិកាលទី២ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាមលើទំរង់ និងគតិនៃច្បាប់ទាំងស្រុង កាលពីថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០០ នាសម័យប្រជុំពេញអង្គលើកទី៣ នីតិកាលទី១ លើកទី១ លើកលែងតែចំណុចទី៤នៃមាត្រាទី៣ ក្នុងជំពូកទី១ ប៉ុន្តែត្រូវបានរដ្ឋសភាធ្វើការបោះឆ្នោតអនុម័តជាចំហ ដោយមិនយល់ព្រមតាមសំណើរបស់

ព្រឹទ្ធសភានាសម័យប្រជុំពេញអង្គលើកទី៥ នីតិកាលទី២ នៅថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០០ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

# ច្បាប់

## ស្តីពី

# ការគ្រប់គ្រងលើការប្រកបវិជ្ជាជីវៈឯកជន

# ក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ

# និង ជំនួយវេជ្ជសាស្ត្រ

***

### ជំពូកទី ១

### បទប្បញ្ញត្តិទូទៅ

មាត្រា ១ .-

ច្បាប់នេះមានគោលដៅកំណត់បែបបទនិងលក្ខខណ្ឌនៃការប្រព្រឹត្តទៅសំរាប់ការគ្រប់គ្រងលើការប្រកបវិជ្ជាជីវៈឯកជនក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រក្នុងព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ២ .-

ត្រូវបានចាត់ទុកជា :

- អ្នកប្រកបវិជ្ជាជីវៈវេជ្ជសាស្ត្រ និងអមវេជ្ជសាស្ត្រ គឺគ្រូពេទ្យ ឱសថការី ទន្តពេទ្យ និងឆ្មប ។
- អ្នកប្រកបវិជ្ជាជីវៈជំនួយវេជ្ជសាស្ត្រគឺ គិលានុបដ្ឋាក គិលានុបដ្ឋាយិកា អ្នកបច្ចេកទេសមន្ទីរពិសោធន៍ អ្នកព្យាបាលដោយចលនា អ្នកបច្ចេកទេសធ្មេញនិងអ្នកប្រកបវិជ្ជាជីវៈប្រហាក់ប្រហែលផ្សេងទៀត ។

មុខវិជ្ជាជីវៈប្រហាក់ប្រហែលដូចមានចែងក្នុងវាក្យខ័ណ្ឌខាងលើ ត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា ៣ ._

មានសិទ្ធិប្រកបវិជ្ជាជីវៈជាអ្នកវេជ្ជសាស្ត្រ អ្នកអមវេជ្ជសាស្ត្រនិងអ្នកជំនួយវេជ្ជសាស្ត្របាន ចំពោះជនណាដែលមានលក្ខណសម្បត្តិដូចខាងក្រោមនេះ :

- មានសញ្ជាតិខ្មែរ
- មានសញ្ញាប័ត្រដែលទទួលស្គាល់ដោយក្រសួងសុខាភិបាល
- បានចុះឈ្មោះក្នុងបញ្ជីសមាជិកគណៈគ្រូពេទ្យ គណៈឱសថការី គណៈទន្តពេទ្យ គណៈឆ្មប គណៈគិលានុប្បដ្ឋាក
- មិនដែលមានទោសពីបទល្មើសព្រហ្មទណ្ឌណាមួយ
- មានសុខភាពគ្រប់គ្រាន់អាចបំពេញការងារបាន ។

មាត្រា ៤ ._

អាចអនុញ្ញាតឲ្យជនបរទេសជាអ្នកវេជ្ជសាស្ត្រ ជាអ្នកអមវេជ្ជសាស្ត្រនិងជាអ្នកជំនួយវេជ្ជសាស្ត្រ ដែលមានការជំនាញឯកទេសខ្ពស់ប្រកបវិជ្ជាជីវៈ ក្នុងព្រះរាជាណាចក្រកម្ពុជា ។ បែបបទនិងល័ក្ខខ័ណ្ឌនៃការអនុញ្ញាត ត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី២

## ការបើក ការកែច្នៃទំហំនិងការបិទសេវាវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ

មាត្រា ៥ ._

ការបើក ការកែទ្រង់ទ្រាយបន្ទប់ពិគ្រោះព្យាបាលជំងឺ បន្ទប់ពិគ្រោះព្យាបាលជំងឺទន្តវេទនសាស្ត្រ (មាត់ធ្មេញ) បន្ទប់ពិគ្រោះស្ត្រីមានផ្ទៃពោះ បន្ទប់សោភ័ណសល្យសាស្ត្រ មន្ទីរពិសោធន៍វេជ្ជសាស្ត្រ មន្ទីរសម្ភពមន្ទីរសំរាកព្យាបាលពហុព្យាបាល សេវាវេជ្ជសាស្ត្រអមវេជ្ជសាស្ត្រឬជំនួយវេជ្ជសាស្ត្រឯកជនផ្សេងទៀត ត្រូវសំរេចដោយប្រកាសរបស់ក្រសួងសុខាភិបាល ។ ក្រោយពីបានទទួលការអនុញ្ញាតពីក្រសួងសុខាភិបាល ហើយត្រូវអនុវត្តតាមនីតិវិធីជាធរមាន ។

ចំពោះការបិទវិញត្រូវសុំច្បាប់ពីក្រសួងសុខាភិបាល ។

មាត្រា ៦ ._

អ្នកមានសិទ្ធិប្រកបវិជ្ជាជីវៈដូចមានចែងក្នុងមាត្រា ៣នៃច្បាប់នេះ អាចមានសិទ្ធិសុំបើក :

- បន្ទប់ពិគ្រោះព្យាបាលជំងឺឯកជនបាន ចំពោះតែវេជ្ជបណ្ឌិត ឬគ្រូពេទ្យមធ្យម
- បន្ទប់ពិគ្រោះព្យាបាលជំងឺទន្តវេទនសាស្ត្រ (មាត់ធ្មេញ) ឯកជនបាន ចំពោះតែទន្តបណ្ឌិត ទន្តពេទ្យ ឬគ្រូពេទ្យឯកទេសមាត់

- បន្ទប់ព្យាបាលដោយចលនាឯកជនបាន ចំពោះតែអ្នកព្យាបាលដោយចលនា
- បន្ទប់ថែទាំជំងឺឯកជនបានចំពោះតែគិលានុបដ្ឋាកមធ្យម ឬគិលានុបដ្ឋាយិកាមធ្យម
- បន្ទប់សោភ័ណសល្យសាស្ត្រឯកជនបាន ចំពោះតែវេជ្ជបណ្ឌិតដែលមានឯកទេសជំនាញផ្នែកនេះ
- មន្ទីរពិសោធន៍វេជ្ជសាស្ត្រឯកជនបាន ចំពោះតែវេជ្ជបណ្ឌិតឱសថបណ្ឌិត ឬឱសថការីឧត្តម ដែលមានឯកទេសជំនាញមន្ទីរពិសោធន៍
- មន្ទីរសម្ភព មន្ទីរសំរាកព្យាបាលពហុព្យាបាលឯកជនបាន ចំពោះតែវេជ្ជបណ្ឌិត ។

ដោយឡែកចំពោះឆ្មបមធ្យមមានសិទ្ធិបើកតែបន្ទប់ពិគ្រោះស្ត្រីមានផ្ទៃពោះឯកជនប៉ុណ្ណោះ ។

មាត្រា ៧ .-

មន្ទីរសម្ភព មន្ទីរសំរាកព្យាបាលពហុព្យាបាលឯកជនទាំងឡាយដែលមានគ្រែសំរាប់អ្នកជំងឺសំរាកព្យាបាល និងមន្ទីរ ពិសោធន៍វេជ្ជសាស្ត្រឯកជនត្រូវមានវត្តមានរបស់អ្នកទទួលខុសត្រូវ ។

ក្នុងករណីអវត្តមានអ្នកទទួលខុសត្រូវ ត្រូវមានអ្នកជំនួស ។ លក្ខណសម្បត្តិនៃអ្នកទទួលខុសត្រូវ និងអ្នកត្រូវជំនួស ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសុខាភិបាល ។

មាត្រា ៨ .-

អ្នកវេជ្ជសាស្ត្រ អ្នកអមវេជ្ជសាស្ត្រឬអ្នកជំនួយវេជ្ជសាស្ត្រមួយរូប មានសិទ្ធិសុំបើកសេវាវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ ឬជំនួយវេជ្ជសាស្ត្រឯកជនរបស់ខ្លួនបានតែមួយកន្លែង ទោះជាអ្នកនោះមានសញ្ញាប័ត្រឯកទេសច្រើនក៏ដោយ ។

មាត្រា ៩ .-

បែបបទនិងល័ក្ខខ័ណ្ឌនៃការសុំបើក សុំកែទ្រង់ទ្រាយ សុំបិទ ព្រមទាំងល័ក្ខខ័ណ្ឌបច្ចេកទេសនៃសេវាវេជ្ជសាស្ត្រ សេវាអមវេជ្ជសាស្ត្រនិងសេវាជំនួយវេជ្ជសាស្ត្រ ឯកជនត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសុខាភិបាល ។

## ជំពូកទី៣

## សមត្ថកិច្ចក្នុងការគ្រប់គ្រងនិងការត្រួតពិនិត្យ

មាត្រា ១០ .-

ការណែនាំ ការគ្រប់គ្រង ការត្រួតពិនិត្យរាល់សកម្មភាពនៃវិជ្ជាជីវៈវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ ជាសមត្ថកិច្ចរបស់ក្រសួងសុខាភិបាល ជំនួយដោយគណៈវិជ្ជាជីវៈសមស្របតាមក្រមសីលធម៌ តាមមុខវិជ្ជាជីវៈនីមួយៗ ។

ការរៀបចំ និងការប្រព្រឹត្តិទៅរបស់គណៈវិជ្ជាជីវៈនីមួយៗ ត្រូវកំណត់ដោយព្រះរាជក្រឹត្យ ។

បទប្បញ្ញត្តិស្តីពីក្រមសីលធម៌តាមមុខវិជ្ជាជីវៈនីមួយៗត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា ១១ .-

ការផ្សព្វផ្សាយជាលក្ខណៈពាណិជ្ជកម្មត្រូវហាមឃាត់ជាដាច់ខាត លើកលែងតែការផ្សព្វផ្សាយក្នុងក្របខ័ណ្ឌវិជ្ជាជីវៈ ដែលមិនប៉ះពាល់ដល់ក្រមសីលធម៌ហើយត្រូវបានកំណត់ដោយប្រកាសរបស់ក្រសួងសុខាភិបាល ។

មាត្រា ១២ .-

ការគ្រប់គ្រងលើការប្រកបវិជ្ជាជីវៈឯកជន ក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ ត្រូវឋិតនៅក្រោមរបបនីតិរួមអំពីពន្ធ និងអាករ លើកលែងតែមានបដិប្បញ្ញត្តិដែលចែងដោយច្បាប់ ។

## ជំពូកទី៤

## ទោសប្បញ្ញត្តិ

មាត្រា ១៣ .-

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន)រៀល ដល់ ៥.០០០.០០០ (ប្រាំលាន)រៀល និងផ្អាកដំណើរការសេវាវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ ពី១ខែទៅ ៣ខែ ឬទោសណាមួយក្នុងចំណោមទោសទាំងពីរនេះដោយពុំទាន់គិតពីបទល្មើសផ្សេងទៀត ចំពោះជនណាដែលបានប្រព្រឹត្តល្មើសនឹងមាត្រា ៥ មាត្រា ៦ មាត្រា ៧ មាត្រា ៨ មាត្រា១១ ឬ មាត្រា១២ នៃច្បាប់នេះ ។

ក្នុងករណីមិនរាងចាល ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ទ្វេមួយជាពីរនិងផ្អាកដំណើរការសេវា ឬបញ្ឈប់ជាស្ថាពរ ។

មាត្រា ១៤ .-

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន)រៀល ដល់ ១០.០០០.០០០ (ដប់លាន)រៀល ចំពោះជនណាដែលរារាំងមិនឲ្យភ្នាក់ងារមានសមត្ថកិច្ចបំពេញភារកិច្ចអធិការកិច្ចរបស់ខ្លួន ដូចមានចែងក្នុងមាត្រា ១០ ខាងលើ ។

មាត្រា ១៥ .-

ត្រូវផ្តន្ទាទោសដូចមានចែងក្នុងមាត្រា ១៣ ឬ ១៤ ចំពោះមន្ត្រីរាជការ ឬជនណាដែលបានឃុបឃិត ឬប្រព្រឹត្តរំលោភលើភារកិច្ចរបស់ខ្លួន ។

## ជំពូកទី៥

## អន្តរប្បញ្ញត្តិ

មាត្រា ១៦ .-

ក្នុងរយៈពេល ៦ (ប្រាំមួយ) ខែយ៉ាងយូរ បន្ទាប់ពីច្បាប់នេះចូលជាធរមានអ្នកប្រកបវិជ្ជាជីវៈវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រឯកជន ដែលក្រសួងសុខាភិបាលបានចេញលិខិតអនុញ្ញាត

ឲ្យបើកសេវាជាផ្លូវការហើយនោះ ត្រូវបំពេញបន្ថែមនូវទំរង់បែបបទឲ្យត្រឹមត្រូវតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

## ជំពូកទី៦

## អវសានប្បញ្ញត្តិ

**មាត្រា ១៧ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍ ។

រាជធានីភ្នំពេញ, ថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ ២០០០

ព្រះហស្តលេខា

នរោត្តម សីហនុ

បានបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

បានជំរាបជូនសម្តេចនាយរដ្ឋមន្ត្រី

ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសុខាភិបាល

ហត្ថលេខា

ហុង ស៊ុនហួត

★★★

## ២– ព្រះរាជក្រឹត្យ

### ព្រះរាជក្រឹត្យ នស/រកត/១១០០/១៨១

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

***

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា